**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៣*៤៤

**តុលាការកំពូល**

សំណុំរឿងរដ្ឋប្បវេណី

លេខៈ ១២៨

ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០០៦

<u>សាលដីកា</u>

លេខៈ ៣៤៥

ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៦

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម **ឌិត មុន្នី** ជាប្រធាន

២-លោក រៀល មួន ជាចៅក្រម

៣-លោក ស៊ិន ឌិម ជាចៅក្រម

៤-លោក ឈិម ស៊ីផល ជាចៅក្រម

៥-លោក គង់ គីរុន ជាចៅក្រម

៦-លោក វ៉ែន សារឿន ជាចៅក្រមរបាយការណ៍

៧-លោក យស់ សូខឿន ជាចៅក្រម

៨-លោក ម៉ុង មុន្នីចរិយា ជាចៅក្រម

៩-លោក យូរ ឧត្តរា ជាចៅក្រម

ក្រឡាបញ្ជី

លោកស្រី **ឌួច ឡានី**

តំណាងមហាអយ្យការ

ឯកឧត្តម **ឌួន ស៊ុនឡេង** ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ០៩"ជ"ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៦ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍រាជធានី :

ដើមចោទឈ្មោះ **អ៊ុំ ចិទថារ៉ន** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរមេផ្ទះ មានទីលំនៅសព្វថ្ងៃភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។ឪពុកឈ្មោះអ៊ុំ កួយ "ស"ម្តាយឈ្មោះយឿន "ស"ប្តីឈ្មោះនុត រុន្ធីមានកូន៧នាក់។

មានមេធាវីលោក ភុំ ប៊ុនផាន់ ។

ចុងចំលើយឈ្មោះ **ឡៅ ចិទធី** (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥៨ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅសព្វថ្ងៃភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។ឪពុកឈ្មោះផ្ញើក"ស"ម្តាយឈ្មោះកុយ រ៉ុង "ស" ប្រពន្ធឈ្មោះអ៊ុំ គិមទី មានកូន៧នាក់ ។

មានមេធាវី ហ៊ុង គឹមស្នួរ ។

**កម្មវត្ថុបណ្តឹង** : ប្តឹងទាមទារដី .

បានឃើញបណ្តឹងសាទុក្ខលេខ ០៩ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៦ របស់ឈ្មោះអ៊ីវ គីមហ៊ាន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ០១"ជ"ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២១០៦ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១២៨ ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០០៦ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០២-៦-២០០៣ របស់អ្នកស្រីអ៊ីវ គីមហ៊ាន បានប្តឹងថា :កាលពីឆ្នាំ១៩៨៣ ឈ្មោះឡៅ ប៊ុនហ៊ី និងប្រពន្ធឈ្មោះអ៊ីវគីមទី ហៅមួយ ត្រូវជាប្អូនបង្កើតរបស់ខ្លួនបានមកខ្ចីដី និងផ្ទះតូចរបស់ខ្លួននៅភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុក-ខេត្តសៀមរាប ស្នាក់នៅជាបណ្តោះអាសន្ន ដោយសន្យាថា ពេលណារកដីនៅបាននិងចេញភ្លាម ។ ដោយខ្លួនគិតថា ជាប្អូនបង្កើតខ្លួន ខ្លួនក៏យល់ព្រមឱ្យស្នាក់នៅទៅ តែពេលខ្លួនត្រូវការយកដីនោះលក់យកលុយដើម្បីមើលជំងឺប្តី បែរជាគេពុំព្រមចេញពីដីរបស់ខ្លួនឡើយ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៨០ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៣ របស់តុលាការខេត្តសៀមរាប ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៣-៦-២០០៣ របស់ដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងតបរបស់ចុងចម្លើយ ប្តឹងសុំសិទ្ធិគ្រប់គ្រងដីទំហំ១៥ម៉ែត្រគុណនឹង១៥ម៉ែត្រ និងប្តឹងទាមទារជំងឺចិត្តចំនួន៣.០០០ដុល្លាអាមេរិក (បីពាន់ដុល្លាអាមេរិក) មានលក្ខណៈត្រឹមត្រូវតាមទំរង់ តែបដិសេធចោល ដោយផ្ទុយនឹងគតិច្បាប់ ។

៣-ទទួលស្គាល់ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ $A_1$ ០៩១៤ ចុះថ្ងៃទី១៥-០២-២០០១ របស់ឈ្មោះនុត វុន្ធី និងនាង អ៊ីវ គីមហ៊ាន ជាដើមចោទ មានលក្ខណៈត្រឹមត្រូវតាមច្បាប់។

៤-សំរេចឱ្យឈ្មោះឡៅ ប៊ុនហ៊ី ជាចុងចំលើយរុះរើផ្ទះចេញពីដីដើមចោទ ។

៥-សំរេចឱ្យឈ្មោះឡៅ ប៊ុនហ៊ី សងប្រាក់ជំងឺចិត្តចំនួន៥០០ដុល្លាអាមេរិក (ប្រាំរយដុល្លាអាមេរិក) ទៅដើមចោទឈ្មោះអ៊ីវ គីមហ៊ាន ។ សុំលើសពីនេះលើកចោល ។

៦-សំរេចឱ្យឈ្មោះឡៅ ប៊ុនហ៊ី បង់ប្រាក់ប្រជាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីង ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥.០០០៛ បូករួម៧០០០៛។ ប្រាក់នេះបានកាត់យកពីប្រាក់៧.០០០៛ ដែលដើមចោទបានបង់រួចហើយ ។ កាលបើហួសឧទ្ធរណ៍ត្រូវបង្គាប់ឱ្យឈ្មោះឡៅ ប៊ុនហ៊ី សងប្រាក់៧.០០០៛នេះទៅដើមចោទវិញ និងឱ្យបង់ពន្ធសមាមាត្រ ១%លើដីដែលតុលាការប្រគល់ឱ្យបន្ថែមទៀត ។ ត្រូវដាក់ចូលថវិការដ្ឋ៨០% និងរង្វាន់ក្រឡាបញ្ជី

ទូទាំងប្រទេស២០៛ ។ ពន្ធសមាមាត្រនេះ ត្រូវបង្គាប់ឱ្យដើមចោទបង់ទុកជាមុនដែរ ទើបបង្គាប់ឱ្យចុងចម្លើយសងទៅឱ្យដើមចោទវិញជាក្រោយ ។

៧-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់ពីរខែ គិតពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៩០ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះឡៅ ប៊ុនហ៊ី ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១៨០ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៣ របស់តុលាការខេត្តសៀមរាប ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការបៀបលេខ ៥"ឈ"ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ចាត់របៀបឱ្យស្ថាប័នមានសមត្ថកិច្ចចុះធ្វើការអង្កេតវាស់វែង គូសប្លង់បង្ហាញទីតាំងនៃដីទំនាស់ និងបញ្ជាក់អំពីប្រវត្តិនៃដីទំនាស់នេះជាមុនសិន មុននឹងសំរេចដល់អង្គសេចក្តី ។ ក្នុងករណីចាំបាច់សាលាឧទ្ធរណ៍នឹងចុះអង្កេតពិនិត្យដល់ទីកន្លែងនៃដីទំនាស់ ។

២-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចំលើយ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៨៤"ឈ"ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៧-១០-២០០៣ របស់ឈ្មោះឡៅប៊ុនហ៊ី ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ១៨០ ចុះថ្ងៃទី២០-៨-២០០៣ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យចោលជាអសារបង់ ។

៣-ក.ប្រគល់ដីទំហំ ABCDA ស្ថិតនៅក្នុងភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ទៅឱ្យចុងចំលើយឈ្មោះឡៅ ប៊ុនហ៊ី កាន់កាប់គ្រប់គ្រង និងចាត់ចែងជាកម្មសិទ្ធិនៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។ មាត្រា៣០ និង ៣៨ ច្បាប់ភូមិបាលចុះថ្ងៃទី៣០-៨-២០០១ ។

ខ.បង្គាប់ឱ្យដើមចោទឈ្មោះអ៊ីវគីមហ៊ាងសងសំណងជំងឺចិត្តចំនួន៥០០ USD ទៅឱ្យឈ្មោះឡៅ ប៊ុនហ៊ី ជាចុងចំលើយនៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

៤-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ គឺពន្ធហ្វឹង និងចុះបញ្ជីក្តី២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ និងអាជ្ញាធរតុលាការ ១០.០០០៛ សរុប ១៣.០០០៛ ។

កាលបើហួសកំណត់ប្តឹងសាទុក្ខ បង្គាប់ឱ្យដើមចោទសងប្រាក់១៣.០០០៛ទៅឱ្យចុងចំលើយ

វិញ ។

បង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រ១%លើតំលៃដី និងជំងឺចិត្តដែលបានសំរេចក្នុងចំណុចទី៣ នៃសាលដីកានេះ ។

៥-សាលដីកានេះជំនុំជំរះនៅថ្ងៃទី២៧-០៤-២០០៤ចំពោះមុខគូក្តី មេធាវីការពារគូក្តី និងប្រកាសជាសាធារណៈនៅថ្ងៃទី០៦-០៥-២០០៤ ចំពោះមុខឈ្មោះអ៊ីវ គឹមហ៊ាន ជាដើមចោទ លោកមេធាវីសួង សុភា កំបាំងមុខឈ្មោះឡៅ ប៊ុនហ៊ុ ជាចុងចំលើយឈ្មោះពឹងធីតា មេធាវីដើមចោទ ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១៤៨ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះអ៊ីវ គឹមហ៊ាន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៤៤"ឈ"ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៧៧ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៥ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ ១៤៨ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះ អ៊ីវ គឹមហ៊ាន ទុកជាត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៤៤"ឈ"ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ២២៧ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៤ របស់ តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រំបងួសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ដែលដើមចោទបានបង់នៅតុលាការកំពូល ចំនួន១៩.០០០៛ គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្លឹងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ។

ហើយតំរូវឱ្យចុងចម្លើយ សងប្រាក់ចំនួន ១៩.០០០៛ នេះទៅដើមចោទវិញ ។

៥-សាលដីកានេះ ជំនុំជំរះនាសវនាការជាសាធារណៈនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៥ និងប្រកាសនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៥ ។

បានឃើញសាលដីការដ្ឋប្បវេណីរបៀបលេខ ៣៧"ជ"ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-អង្កេតបន្ថែមសួរបញ្ជាក់សាក្សីឈ្មោះឃុន និងវាយតំលៃដី និងផ្ទះទំនាស់នៅឆ្នាំ១៩៨០ ។

២-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ០១"ជ" ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលជំនុំជំរះសំណុំរឿងក្តីរដ្ឋប្បវេណីលេខ ៣៨ ចុះថ្ងៃទី២១-០៦-២០០៥ របស់សាលាឧទ្ធរណ៍តាមអំណាចសាលដីកាតុលាការកំពូល ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ១៨០ ចុះថ្ងៃទី២០-០៨-២០០៣ របស់តុលាការខេត្តសៀមរាបឧត្តរមានជ័យ ចោលជាអសារបង់ ។

៣-ប្រគល់ដីទាស់ដែលមានទំហំ ១៥ម x១៥ម ចំណុច ABCD ស្ថិតនៅភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុកសៀមរាប-ខេត្តសៀមរាប តាមគំនូសប្លង់ដីទាស់ចុះថ្ងៃទី២៣-៣-២០០៤ របស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុកសៀមរាបឱ្យទៅឈ្មោះឡៅ ប៊ុនហ៊ី កាន់កាប់អាស្រ័យផង និងចាត់ចែងនៅពេលសាលដីកាចូលជាស្ថាពរតាមមាត្រា ៣០ នៃច្បាប់ភូមិបាល ចុះថ្ងៃទី៣០-០៨-២០០១ ។

៤-បង្គាប់ឱ្យដើមចោទឈ្មោះអ៊ីវ គីមហ៊ាន សងសំណងជំងឺចិត្តចំនួន ៥០០$ (ប្រាំរយដុល្លាអាមេរិក) ទៅចុងចំលើយ ។ សំណូមពរលើសពីនេះបដិសេធចោល ។

៥-កាត់យកប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍គឺពន្ធហ្វឹង និងពន្ធចុះបញ្ជីក្តី ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥០០០៛ និងលើអាជ្ញាធរតុលាការ ៥០០០៛ សរុប ១៣.០០០៛ និងបង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រចំនួន១% លើតំលៃដីទាស់ដែលប្រាក់ពន្ធសមាមាត្រនេះចំនួន៨០% ដាក់ចូលថវិការដ្ឋ និងចំនួន ២០% បានជារង្វាន់ក្រឡាបញ្ជីទូទាំងព្រះរាជាណាចក្រកម្ពុជា ។

៦-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ ចុងចំលើយ និងមេធាវីហុង គីមសួន, មេធាវីអ៊ាង សុភ័ក្រ្ត ។

បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ០៩ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៦ របស់ឈ្មោះអ៊ីវ គីមហ៊ាន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ០១"ជ"ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី១២ខែមេសា ឆ្នាំ២០០៦ របស់លោកមេធាវីភុំ ប៊ុនជាន់ និងលោកស្រី អ៊ីវ គីមហ៊ាន ។

បានឃើញសារណាឆ្លើយតបចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ របស់ឈ្មោះឡៅ ប៊ុនហ៊ី។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : រឿងនេះ គឺជារឿងប្តឹងទាមទារដី ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្តាប់ចំលើយរបស់ឈ្មោះអ៊ីវ គិមហ៊ាន នាពេលសវនការថា :នៅឆ្នាំ១៩៨០ ខ្លួនបានទិញដីពីឈ្មោះឡែម រឿម ក្រោយមកនៅឆ្នាំ១៩៨៣ ឈ្មោះឃុន បានមកសុំដីខ្លួនស្នាក់នៅបណ្តោះអាសន្ន ហើយបានសង់ផ្ទះនៅលើដីនេះ ។ ពេលនោះសន្តិសុខមិនមានសុវត្ថិភាពឈ្មោះឡៅ ប៊ុនហ៊ុ និងប្រពន្ធបានមកសុំដីនោះនៅបន្តពីឈ្មោះឃុន ដោយទិញសំបកផ្ទះតូចពីឈ្មោះឃុន នៅបណ្តោះអាសន្ន ដោយយល់ថា បងបង្កើត ខ្លួនក៏យល់ព្រមឱ្យដីនោះនៅបន្ត តែបានសន្យាថា នៅពេលរកដីបានគេនឹងរើចេញភ្លាម ។ ប៉ុន្តែនៅពេលខ្លួនត្រូវការដីគេ មិនព្រមរើទេ រហូតប្តឹងផ្តល់គ្នាដល់តុលាការ ។ សព្វថ្ងៃនេះខ្លួនមានប្លង់កម្មសិទ្ធិត្រឹមត្រូវតាមច្បាប់ ហើយពេលសុរិយោដីវាស់វែងដើម្បីធ្វើប្លង់គ្មាននរណាតវ៉ាទេ ។ អ្នកជិតខាងក៏ដឹងថា ដីនេះខ្លួនទិញដែរ ។

បានស្តាប់ចំលើយរបស់ឈ្មោះឡៅ ប៊ុនហ៊ុ នាពេលសវនាការថា : ខ្លួនមិនបានសុំដីឈ្មោះអ៊ីវ គិមហ៊ាន ស្នាក់នៅនោះទេ គឺខ្លួនទិញពីឈ្មោះឃុន នៅឆ្នាំ១៩៨០ គឺទិញទាំងផ្ទះទាំងដីតំលៃ ០៣ជី ហើយក៏បានចូលរស់នៅលើដីនេះរហូតមក នរណាក៏ដឹងដែរថា ខ្លួនទិញទាំងដី ទាំងផ្ទះ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកគុំប៊ុនផាន់ ជាមេធាវីការពារឱ្យដើមចោទបានសន្និដ្ឋានថា :សុំឯកឧត្តមប្រធាននិងក្រុមប្រឹក្សាជំនុំជំរះតុលាការកំពូល បដិសេធចោលសាលដីកាសាលាឧទ្ធរណ៍លេខ ០១"ជ"ចុះថ្ងៃទី០៥-០១-២០០៦ ទុកជាអសារបង់ទាំងមូល និងសុំតំកល់សាលក្រមលេខ ១៨០ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៣ របស់តុលាការខេត្តសៀមរាប និងសុំទទួលស្គាល់សិទ្ធិកម្មសិទ្ធិរបស់ដើមចោទដែលមានក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់លេខ A1 ០៨១៤ ចុះថ្ងៃទី ១២-០២-២០០១ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកហុង គីមសួន ជាមេធាវីការពារឱ្យចុងចំលើយបានលើកឡើងថា : ការដែលអ្នកស្រីអ៊ីវ គិមហ៊ាន ថាកូនក្តីខ្លួនសុំដីគាត់ស្នាក់នៅនោះគឺគ្មានឯកសារណាបញ្ជាក់ទេ គឺគ្រាន់តែថានឹងមាត់ ។

ដីនោះគឺកូនក្តីខ្លួនបានទិញពីឈ្មោះឃុន គឺទិញទាំងដី ទាំងផ្ទះ បើទិញតែផ្ទះ ម្ល៉េះកាលនោះត្រូវលើកកូនផ្ទះចេញហើយ ព្រោះនៅក្នុងឆ្នាំ១៩៨០ នោះគ្មានមូលដ្ឋានណាបញ្ជាក់ពីការទិញលក់ នោះទេ ។

សំណូមពរ : សុំឱ្យក្រុមប្រឹក្សាជំនុំជំរះ តំកល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការទាំងមូល និងសុំបំបែកប្លង់កម្មសិទ្ធិ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចំលើយរបស់គូភាគី ,និងសេចក្តីសន្និដ្ឋានរបស់មេធាវីនៃគូភាគី .
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ០៩ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៦ របស់ឈ្មោះ អ៊ីវ គីមហ៊ាន ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានដោយយោង តាមមាត្រា១៨នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦នៃនីតិវិធី ព្រហ្មទណ្ឌដែលមានអនុភាពអនុវត្តក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

- យល់ឃើញថា មានភស្តុតាងច្បាស់លាស់បញ្ជាក់ថា ចុងចំលើយពិតជាបានចូលមករស់ នៅផ្ទះនិងភាគខ្លះនៃដីទំនាស់តាំងតែពីឆ្នាំ១៩៨០ មកម្ល៉េះ ហើយដើមចោទទើបតែប្តឹងទាមទារក្នុងឆ្នាំ ២០០៣ នេះទេ ដូចនេះទោះបីជាចុងចំលើយខ្ចីដីដើមចោទស្នាក់នៅមែន ក៏ដើមចោទថ្លោះសិទ្ធិក្នុង ការប្តឹងទាមទារហើយ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចប្រគល់ដីទំនាស់ ABCD ទំហំ១៥មx ១៥ម ឱ្យចុងចំលើយគ្រប់គ្រងនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះគ្មានភស្តុតាងបញ្ជាក់ថា ដីដែល ចុងចំលើយគ្រប់គ្រងនោះមានព្រំជារបងច្បាស់លាស់លើដីទំហំ ១៥ម x ១៥ម នោះឡើយ ហើយ ម្យ៉ាងទៀតបានប៉ះពាល់ដល់សិទ្ធិរបស់ដើមចោទក្នុងការចេញចូលទៅផ្ទះផ្នែកខាងក្រោយ ។

- យល់ឃើញថា នៅលើប្លង់ដីទំនាស់ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ២០០៤ របស់ការិយាល័យ រៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុកសៀមរាប តុលាការកំពូលគប្បីកំណត់ចំណុច M ,N សំរាប់សំគាល់ព្រំដីផ្នែកខាងជើងនៃដីទំនាស់ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចឱ្យដើមចោទសងប្រាក់ជំងឺចិត្តចំនួន៥០០ ដុល្លា ឱ្យចុងចំលើយនោះ ពុំបានលើកបង្ហាញក្នុងសំអាងហេតុរបស់ខ្លួនឡើយ ។

- យល់ឃើញ សាលដីការដ្ឋប្បវេណីលេខ០១"ជ"ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៦របស់ សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ច្បាប់ រីឯគតិច្បាប់ ខុសខ្លះ ត្រូវខ្លះ ប៉ុន្តែដើម្បីងាយស្រួលក្នុងការសរសេរ គប្បីបដិសេធចោលទាំងមូល ហើយសំរេច ជាថ្មីឡើងវិញ ។

### ហេតុដូច្នេះ
### វិនិច្ឆ័យសេចក្តីទំនាស់ចុះមុខភាគី

១-ទទួលបណ្តឹងសាទុក្ខលេខ០៩ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៦របស់អ្នកស្រី អ៊ីវ គីមហ៊ាន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែគតិច្បាប់ខុសខ្លះ ត្រូវខ្លះ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ០១"ជ"ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៦របស់ សាលាឧទ្ធរណ៍ទាំងមូល ។

៣-ប្រគល់ដីទំនាស់ DMNC ដែលមានទំហំជ្រុង /DM/=/CN/=12m និង /MN/=/DC/=15m ឱ្យទៅចុងចំលើយគ្រប់គ្រង និងកាន់កាប់ រីឯចំណែកដែលនៅសល់ត្រូវ ប្រគល់ឱ្យដើមចោទ ។

៤-បង្គាប់ឱ្យចុងចំលើយរុះរើវត្ថុ និងការរុះទាំងពួងចេញពីចំណែកដីដែលត្រូវប្រគល់ឱ្យ ដើមចោទ ។

៥-បង្គាប់ឱ្យសមត្ថកិច្ចជំនាញខាងរៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី កែតំរូវប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដីរបស់ដើមចោទ តាមការសំរេចរបស់តុលាការកំពូល ។

៦-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន១៩.០០០រ ដែលដើមចោទបានបង់ទុកនៅតុលាការកំពូលគឺ:

-ពន្ធចុះបញ្ជីក្ដី និងពន្ធហ្មឹងចំនួន៤.០០០រ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រ សរុប ១៩.០០០រ ។

បង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រ១%លើតំលៃដែលត្រូវប្រគល់ឱ្យចុងចំលើយ ។

៧-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៦។